ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា**

# សេចក្ដីសម្រេច
# ស្ដីពី
# ការបង្កើតក្រុមប្រឹក្សាវិទ្យាសាស្ត្រ
# នៃ
# វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

*នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា*

*សម្រេច*

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាវិទ្យាសាស្ត្រដែលជាសេនាធិការរបស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាដើម្បីធានាគុណភាពនៃការអប់រំ គុណភាពនៃការស្រាវជ្រាវវិទ្យាសាស្ត្រ និងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានរបស់វិទ្យាស្ថានប្រកបដោយនិរន្តរភាព។

**ប្រការ២.-**

ក្រុមប្រឹក្សាវិទ្យាសាស្ត្រនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - នាយក | ប្រធាន |
| - នាយករង | អនុប្រធាន |
| - ព្រឹទ្ធបុរស | សមាជិក |
| - ប្រធានមជ្ឈមណ្ឌល | សមាជិក |
| - ប្រធានដេប៉ាតឺម៉ង់ | សមាជិក |
| - មន្ត្រីទទួលបន្ទុកកិច្ចការក្រោយបរិញ្ញាបត្រ | សមាជិក |
| - មន្ត្រីទទួលបន្ទុកកិច្ចការបរិញ្ញាបត្រ និងបរិញ្ញាបត្ររង | សមាជិក |
| - ប្រធានការិយាល័យ | សមាជិក |
| - ប្រធានផ្នែក | សមាជិក |

**ប្រការ៣.-**

ក្រុមប្រឹក្សាវិទ្យាសាស្ត្រអាចបង្កើតគណៈកម្មការ ឬគណៈកម្មការអចិន្ត្រៃយ៍នានាក្នុងគោលបំណងបម្រើឲ្យផលប្រយោជន៍រួមរបស់វិទ្យាស្ថាន។ សមាជិកនៃគណៈកម្មការត្រូវជ្រើសចេញពីសមាជិកនៃក្រុមប្រឹក្សាវិទ្យាសាស្ត្រដែលមានឧបនិស្ស័យតែមួយ ឬប្រហាក់ប្រហែលគ្នា ឬចម្រុះអាស្រ័យលើតម្រូវការចាំបាច់ជាក់ស្តែង។

**ប្រការ៤.-**

ក្រុមប្រឹក្សាវិទ្យាសាស្ត្រមានភារកិច្ចដូចតទៅ៖

- កសាងផែនការយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ គោលនយោបាយ និងផែនការសកម្មភាពរបស់វិទ្យាស្ថាន
- តាមដាន និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ គោលនយោបាយ និងផែនការសកម្មភាពរបស់វិទ្យាស្ថាន
- ធ្វើកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ
- រកជំនួយបច្ចេកទេស សម្ភារ ហិរញ្ញវត្ថុ ។ល។ សម្រាប់គាំទ្រវិទ្យាស្ថាន
- រៀបចំ និងជ្រើសរើសនិស្សិតឲ្យចូលរៀនក្នុងវិទ្យាស្ថាន
- តាមដាន និងអភិវឌ្ឍកម្មវិធីអប់រំ និងកម្មវិធីស្រាវជ្រាវវិទ្យាសាស្ត្ររបស់វិទ្យាស្ថាន
- រៀបចំការប្រឡងនានារបស់វិទ្យាស្ថាន
- តាមដាន និងវាយតម្លៃការសិក្សារបស់និស្សិត និងការងាររបស់បុគ្គលិករបស់វិទ្យាស្ថាន
- ជ្រើសរើសបុគ្គលិកសម្រាប់បម្រើការនៅវិទ្យាស្ថាន
- វាយតម្លៃស្នាដៃប្រចាំឆ្នាំរបស់បុគ្គលិកវិទ្យាស្ថាន
- សម្របសម្រួលការងារពាក់ព័ន្ធនានា
- ពិនិត្យ និងអនុម័តការបង្កើតគណៈកម្មការ និងគណៈកម្មការអចិន្ត្រៃយ៍នានាក្នុងវិទ្យាស្ថាន។

**ប្រការ៥.-**

ប្រធានក្រុមប្រឹក្សាវិទ្យាសាស្ត្រមានភារកិច្ចកោះប្រជុំ និងកំណត់របៀបវារៈនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាវិទ្យាសាស្ត្រ។

**ប្រការ៦.-**

សមាជិកនៃក្រុមប្រឹក្សាវិទ្យាសាស្ត្រត្រូវចូលរួមប្រជុំតាមការអញ្ជើញពីប្រធានក្រុមប្រឹក្សាវិទ្យាសាស្ត្រ។

**ប្រការ៧.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាវិទ្យាសាស្ត្រនៃដេប៉ាតឺម៉ង់ និងការិយាល័យដែលជាសេនាធិការរបស់ក្រុមប្រឹក្សាវិទ្យាសាស្ត្រនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ដើម្បីធានាគុណភាពនៃការអប់រំ គុណភាពនៃការស្រាវជ្រាវវិទ្យាសាស្ត្រ គុណភាពនៃការងារ និងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានរបស់វិទ្យាស្ថាននៅតាមដេប៉ាតឺម៉ង់ និងការិយាល័យ ប្រកបដោយនិរន្តរភាព។

**ប្រការ៨.-**

ក្រុមប្រឹក្សាវិទ្យាសាស្ត្រនៃដេប៉ាតឺម៉ង់/ការិយាល័យមានសមាសភាពដូចខាងក្រោម៖

- ប្រធានដេប៉ាតឺម៉ង់/ការិយាល័យ ប្រធាន

- អនុប្រធានដេប៉ាតឺម៉ង់/ការិយាល័យ អនុប្រធាន
- សាស្ត្រាចារ្យ និងបុគ្គលិក សមាជិក

**ប្រការ៩.-**

ក្រុមប្រឹក្សាវិទ្យាសាស្ត្រនៃដេប៉ាតឺម៉ង់/ការិយាល័យមានភារកិច្ចដូចតទៅ៖

- ចូលរួមកសាងផែនការអភិវឌ្ឍន៍ ផែនការសកម្មភាព និងផែនការប្រតិបត្តិរបស់ដេប៉ាតឺម៉ង់/ការិយាល័យ
- ធ្វើកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ
- ជួយស្វែងរកជំនួយបច្ចេកទេស សម្ភារ ហិរញ្ញវត្ថុ ។ល។ សម្រាប់គាំទ្រវិទ្យាស្ថាន
- ចូលរួមជ្រើសរើសនិស្សិតឲ្យចូលរៀននៅវិទ្យាស្ថាន
- ចូលរួមអភិវឌ្ឍកម្មវិធីអប់រំ និងកម្មវិធីស្រាវជ្រាវវិទ្យាសាស្ត្ររបស់ដេប៉ាតឺម៉ង់/ការិយាល័យ
- សម្របសម្រួលការងារដែលពាក់ព័ន្ធនឹងដេប៉ាតឺម៉ង់/ការិយាល័យ
- ចូលរួមរៀបចំការប្រឡងនានា
- តាមដាន វាយតម្លៃការសិក្សា និងការងារនៅដេប៉ាតឺម៉ង់/ការិយាល័យ
- ចូលរួមជ្រើសរើសបុគ្គលិកសម្រាប់បម្រើការនៅដេប៉ាតឺម៉ង់/ការិយាល័យ

**ប្រការ១០.-**

ប្រធានក្រុមប្រឹក្សាវិទ្យាសាស្ត្រនៃដេប៉ាតឺម៉ង់/ការិយាល័យមានភារកិច្ចកោះប្រជុំ និងកំណត់របៀបវារៈនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាវិទ្យាសាស្ត្រនៃដេប៉ាតឺម៉ង់/ការិយាល័យ។

**ប្រការ១១.-**

សមាជិកនៃក្រុមប្រឹក្សាវិទ្យាសាស្ត្រនៃដេប៉ាតឺម៉ង់/ការិយាល័យត្រូវចូលរួមប្រជុំតាមការអញ្ជើញពីប្រធានក្រុមប្រឹក្សាវិទ្យាសាស្ត្រដេប៉ាតឺម៉ង់/ការិយាល័យ។

**ប្រការ១២.-**

ក្រុមប្រឹក្សាវិទ្យាសាស្ត្រនៃដេប៉ាតឺម៉ង់/ការិយាល័យត្រូវពិនិត្យរាល់បញ្ហាទាំងអស់ដែលទាក់ទងទៅនឹងកិច្ចការនានាស្តីពីការសិក្សា ការបង្រៀន ការបណ្តុះបណ្តាល ការស្រាវជ្រាវវិទ្យាសាស្ត្រ វឌ្ឍនភាពការងារក្រោមសមត្ថកិច្ចរបស់ខ្លួន ហើយធ្វើរបាយការណ៍ពាក់ព័ន្ធជូនទៅក្រុមប្រឹក្សាវិទ្យាសាស្ត្រវិទ្យាស្ថាន។

**ប្រការ១៣.-**

ក្រុមប្រឹក្សាវិទ្យាសាស្ត្រវិទ្យាស្ថានត្រូវពិនិត្យរាល់បញ្ហាទាំងអស់ដែលទាក់ទងទៅនឹងកិច្ចការនានាស្តីពីការសិក្សា ការបង្រៀន ការបណ្តុះបណ្តាល ការស្រាវជ្រាវវិទ្យាសាស្ត្រ វឌ្ឍនភាពការងាររបស់វិទ្យាស្ថាន ហើយធ្វើរបាយការណ៍ពាក់ព័ន្ធជូនទៅក្រុមប្រឹក្សាភិបាលវិទ្យាស្ថាន។

**ប្រការ១៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥.-**

សេចក្ដីសម្រេចនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៤

**នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា**

Institut de Technologie du Cambodge

បណ្ឌិត អ៊ុម រម្យណី